កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and the WSD Handa Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ១១

ក្នុងអំឡុងពេលពេញពីរថ្ងៃគត់នៃសវនាការលើភស្តុតាងធ្វើជាសាធារណៈនៅសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូង បានស្តាប់សក្ខីកម្មរបស់សាក្សីតែមួយរូបគត់ គឺលោក **វ៉ាន់ សឿន** ដែលជាអតីតឆ្មាំសន្តិសុខ និងជានីរសារនៅមន្ទីរសន្តិសុខក្រាំងតាចាន់។ សេចក្តីស្នើសុំរបស់ក្រុមមេធាវីការពារក្តីពាក់ព័ន្ធនឹងការបន្តដាក់បង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវឯកសារ ដែលបានមកពីការស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបសួរលើសំណុំរឿង០០៣ និង ០០៤ ចូលទៅក្នុងសំណុំរឿង០០២ វគ្គទី២ បានធ្វើឲ្យសវនាការនាសប្តាហ៍នេះប្រព្រឹត្តទៅក្នុងរយៈពេលយ៉ាងខ្លី។ បញ្ហានីតិវិធីខាងលើនេះ ត្រូវបានដាក់បញ្ចូលរួមគ្នាក្នុងសេចក្តីប្រកាសរបស់សហចៅក្រមស៊ើបសួរអន្តរជាតិ កាលពីថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ នេះ ស្តីពីការចោទប្រកាន់ក្រោមការត្រួតពិនិត្យកំបាំងមុខលើជនសង្ស័យចំនួនពីររូប នៅក្នុងសំណុំរឿងទាំងពីរនេះ ក្នុងដំណាក់កាលនៃកិច្ចស៊ើបអង្កេត។ អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម នឹងធ្វើការសង្ខេប និងការវិភាគលើសេចក្តីប្រកាសនៃការចោទប្រកាន់ទាំងនេះ ក្នុងរបាយការណ៍ដោយឡែកមួយនាពេលឆាប់ៗនេះ។ ទោះបីជាយ៉ាងនេះក្តី របាយការណ៍នេះ ពិភាក្សាលើការបន្តដាក់បង្ហាញឯកសារដែលបានមកពីការស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបសួរ ចូលទៅក្នុងសំណុំរឿង០០២ វគ្គទី២នេះ ដោយសារអង្គជំនុំជម្រះសាលាដំបូង បានបើកកិច្ចប្រជុំជាសាធារណៈស្តីពីការគ្រប់គ្រងសវនាការ ដើម្បីអនុញ្ញាតឲ្យភាគីទាំងអស់ធ្វើការកត់សម្គាល់លើផលប៉ះពាល់នៃដំណាក់កាលជំនុំជម្រះនាពេលថ្មីៗនេះ និងការកំណត់លំដាប់លំដោយនៃសំណុំរឿងបន្តបន្ទាប់។ ជាងនេះទៅទៀតនេះ របាយការណ៍នេះ ក៏សង្ខេបផងដែរនូវសក្ខីកម្មរបស់សាក្សី **វ៉ាន់ សឿន** ហៅ “**សួន**” ដែលបានរៀបរាប់ពីតួនាទីរបស់គាត់នៅក្នុង

មន្ទីរសន្តិសុខ ចំណេះដឹងរបស់គាត់ស្តីពីរចនាសម្ព័ន្ធរដ្ឋបាលរបស់មន្ទីរសន្តិសុខ ហើយនិងការសង្កេតរបស់គាត់ជុំវិញការចោទប្រកាន់ពីអំពើឃោរឃៅក្នុងមន្ទីរសន្តិសុខ។ របាយការណ៍នេះ ក៏ធ្វើការវិភាគផងដែរលើភាពខ្វះខាតរបស់អង្គជំនុំជម្រះសាលាដំបូងលើការណែនាំឲ្យបានច្បាស់លាស់ ដោយគោរពលើភាពឯកជនដែលត្រូវបានការពារដល់ជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ បន្ទាប់ពីបញ្ហានេះ ត្រូវបានលើកឡើងសាជាថ្មីម្តងទៀត ក្នុងអំឡុងពេលនៃការចោទសួរដេញដោលលើសាក្សីរូបនេះ ពីសំណាក់មេធាវីការពារក្តី **វិច ទ័រ** (Victor Koppe) ក្នុងសប្តាហ៍នេះ។

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ ចូហាន់ណា ហាម៉ាក គីនប៉ហ្គ (Johanna Hamark Kindborg), ហ៊ុយ សម្បូណ៌, ឡូញ ង៉ែត, ដាញ៉ែល ម៉ាតថេស៍ (Daniel Mattes), តាយ លីណា, ហ្វីប៊ី សាប៊ីន (Phoebe Sabin), ភីនីឡូភី វ៉ាន់ ធូល (Penelope Van Tuyl) និង វង្ស ឧត្តម ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និង ការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោងផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌ អន្តរជាតិ (WSD Handa Center) ដែលកាលពីមុន ត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាមប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSD HANDA CENTER FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University